III. ផ្នែកការគណៈរដ្ឋមន្ត្រី

អនុក្រឹត្យ

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៩៤

អនុក្រឹត្យលេខ ៣២ អនក្រ

ស្តីពីការកំណត់រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ ឃុំ សង្កាត់

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ :- រៀបចំរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ ឃុំ មានដូចខាងក្រោមនេះ ៖

១- មេឃុំ

២- ជំទប់លេខ ១

៣- ជំទប់លេខ ២

៤- ជំទប់លេខ៣

៥- ជំនួយការរដ្ឋបាលឃុំ ចំនួន មួយរូប ។

មាត្រា ២ : រៀបចំរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់សង្កាត់ មានដូចខាងក្រោមនេះ ៖

១- ចៅសង្កាត់

២- ចៅសង្កាត់រងទី ១

៣- ចៅសង្កាត់រងទី ២

៤- ជំនួយការរដ្ឋបាលសង្កាត់ចំនួន ២ រូប ។

មាត្រា ៣ : ភូមិគឺជាចំណែកមួយនៃឃុំ ឬ សង្កាត់ និង ជារចនាសម្ព័ន្ធជំនួយការរដ្ឋបាលថ្នាក់ឃុំ សង្កាត់ ដែលគ្រប់គ្រងដោយមេភូមិ ។

មាត្រា ៤ : តួនាទីភារកិច្ចជាក់ស្តែង នៃរចនាសម្ព័ន្ធរដ្ឋបាល ថ្នាក់ឃុំ សង្កាត់ និង ការបែងចែកភារកិច្ចជូនមន្ត្រី ឃុំសង្កាត់ ដែលមានស្រាប់ទៅតាមរចនាសម្ព័ន្ធនេះ អាស្រ័យដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាអ្នកកំណត់ណែនាំ ។

មាត្រា ៥ : បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់គ្រងក្រសួង រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការគ្រប់គ្រង រដ្ឋលេខាធិការដ្ឋានត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃ ឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឬទ្ធិ	ហ៊ុន សែន

អនុក្រឹត្យលេខ ៣៣ អនក្រ

ស្តីពីការបង្កើតគណៈកម្មការ ពិនិត្យការដេញថ្លៃ និងការសាងសង់ព្រលានយន្តហោះ ពោធិចិនតុង

រាជធានីភ្នំពេញ, ថ្ងៃទី៩ខែ កក្កដា ឆ្នាំ១៩៩៤

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន

សំរេច

មាត្រា ១ : បង្កើតគណៈកម្មការត្រួតពិនិត្យការដេញថ្លៃអន្តរជាតិ និង ការសាងសង់ព្រលានយន្តហោះពោធិចិនតុងដែលមានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តម ត្រាំ អ៊ីវតឹក អនុរដ្ឋលេខាធិការ ក្រសួងសាធារណៈការ និង ដឹកជញ្ជូនប្រធាន

២- ឯកឧត្តម ប៉ុក សំអែល អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល កម្ពុជា អនុប្រធាន

៣- ឯកឧត្តម ម៉ម សូផាណា ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី ២ សមាជិក

៤- ឯកឧត្តម សុខ ចិន្តា អនុរដ្ឋលេខាធិការ ក្រសួងទេសចរណ៍ សមាជិក

៥- ឯកឧត្តម គៀង វ៉ាង អនុរដ្ឋលេខាធិការ ក្រសួង មហាផ្ទៃ សមាជិក

៦- លោក GANS BRUYNTJES ទីប្រឹក្សាឯកឧត្តមទេសរដ្ឋមន្ត្រី អ៊ឹង ហួត សមាជិក

៧- លោក កៅ ម៉ិន ហុង ទីប្រឹក្សាច្បាប់ ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៨- លោក ឆយ វិមលរាជ ប្រធានការិយាល័យគ្រប់គ្រងទុន និង វិនិយោគ- [illegible] ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក

៩- លោក រស្មៀង ហាក់ អគ្គនាយក ក្រសួងសាធារណការ និង ដឹកជញ្ជូន សមាជិក

១០- លោក រស់ ម្ហូរ៉ាត ស្ថាបត្យករ សមាជិក

១១- តំណាង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

១២- លោក ឃិត ម៉ុណ្ណា នាយករង អគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងសាធារណការ និង ដឹកជញ្ជូន សមាជិក

មាត្រា ២ : គណៈកម្មការនេះមានភារកិច្ចពិនិត្យ និង ជ្រើសរើសអ្នកវិនិយោគទុនដែលត្រូវ អនុញ្ញាតឲ្យសាងសង់ព្រលានយន្តហោះពោធិ៍ចិនតុង ។

មាត្រា ៣ : ក្រសួងសាធារណការ និង ដឹកជញ្ជូននិងអាជ្ញាធរអាកាសចរស៊ីវិលកម្ពុជាទទួលបន្ទុកក្នុងការរៀបចំសិទ្ធិសញ្ញា និង ការត្រួតពិនិត្យក្នុងការសាងសង់អោយបានគ្រប់គ្រាន់តាមលក្ខណៈបច្ចេកទេស ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីរដ្ឋលេខាធិការ នៃ ក្រសួងរដ្ឋលេខាធិការដ្ឋានពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឬទ្ធិ	ហ៊ុន សែន

* * *

អនុក្រឹត្យលេខ ៣៩ អនក្រ
ស្តីពីការបង្កើតបញ្ជាការដ្ឋានតំបន់
ប្រតិបត្តិការ សឹករងក្រុងកែប និង បូកគោ

° ° °

រាជធានី ភ្នំពេញថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ១៩៩៤

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ័ន្ម ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី ទី១ និងនាយករដ្ឋមន្ត្រីទី ២ នៃព្រះរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតអគ្គសេនាធិការដ្ឋានកងទ័ពជាតិកម្ពុជា ។
- ផ្អែកតាមសំណូមពរចាំបាច់ នៃការកសាងកងយោធពលខេមរភូមិន្ទចំពោះមុខ និង ដើម្បីការពាររឹងមាំ ក្រុងកែប និង បូកគោ ។
- ផ្អែកតាមសំណើរបស់នាយអគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ ។

សំរេច

មាត្រា ១ : ត្រូវបានបង្កើតបញ្ជាការដ្ឋានតំបន់ប្រតិបត្តិការសឹករង ក្រុងកែប និងបូកគោ ស្ថិតនៅក្រោមការដឹកនាំបញ្ជាផ្ទាល់របស់អគ្គសេនាធិការ។

មាត្រា ២ : រចនាសម្ព័ន្ធចាត់តាំងភារកិច្ច និងសិទ្ធរបស់តំបន់ប្រតិបត្តិ ការសឹករង ក្រុងកែប និង បូកគោ អាស្រ័យដោយ អគ្គសេនាធិការកំណត់ ។

មាត្រា ៣ : ប្រគល់ជូនអគ្គសេនាធិការកងយោធពលខេមរភូមិន្ទធ្វើការកំណត់ភារកិច្ច

និងពេលវេលាជាក់ស្តែងក្នុងការរៀបចំបញ្ហាការដ្ឋានតំបន់ប្រតិបត្តិការសឹករងខាងលើ ។

មាត្រា ៤ : អគ្គសេនាធិការកងយោធពលខេមរភូមិន្ទត្រូវទទួលបន្ទុកអនុវត្តន៍អនុក្រឹត្យនេះ ។

មាត្រា៥ : អនុក្រឹត្យនេះចូលជាធរមានចាប់ពីពេលឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

ជ. រាជរដ្ឋាភិបាល

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
សម្តេចក្រុមព្រះ នរោត្តមរណឫទ្ធិ	សម្តេច ហ៊ុន សែន

• • •

អនុក្រឹត្យលេខ ៣៥ អនក្រ
ស្តីពីការបង្កើតកងពលធំថ្មើរជើង

ភ្នំពេញថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ១៩៩៤

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យរបស់ ព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី ២ នៃព្រះរាជរដ្ឋាភិបាលកម្ពុជា ។
-បានឃើញ [illegible] ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការ [illegible]

និងពេលវេលាជាក់ស្ដែងក្នុងការរៀបចំបញ្ហាការដ្ឋានតំបន់ប្រតិបត្តិការសឹករងខាងលើ ។

មាត្រា ៤ : អគ្គសេនាធិការកងយោធពលខេមរភូមិន្ទត្រូវទទួលបន្ទុកអនុវត្តន៍អនុក្រឹត្យនេះ ។

មាត្រា៥ : អនុក្រឹត្យនេះចូលជាធរមានចាប់ពីពេលឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

ជ. រាជរដ្ឋាភិបាល

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
សម្ដេចក្រុមព្រះ នរោត្តមរណឫទ្ធិ	**សម្ដេច ហ៊ុន សែន**

• • •

អនុក្រឹត្យលេខ ៣៥ អនក្រ
ស្ដីពីការបង្កើតកងពលធំថ្មើរជើង

ភ្នំពេញថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ១៩៩៤

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្ដីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី ២ នៃព្រះរាជរដ្ឋាភិបាលកម្ពុជា ។

-បាន [illegible] ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្ដីពី [illegible]

អគ្គសេនាធិការដ្ឋានកងទ័ពជាតិកម្ពុជា ។

-ផ្អែកតាមសំណូមពរចាំបាច់ នៃការកសាងកងយោធពលខេមរភូមិន្ទ ចំពោះមុខ។

- ផ្អែកតាមសំណើរបស់នាយអគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ ។

សំរេច

មាត្រា១: ត្រូវបានបង្កើត ១ កងពលធំថ្មើរជើងស្ថិតនៅក្រោមការដឹកនាំបញ្ជាផ្ទាល់របស់យោធភូមិភាគទី៣ ដោយយកសញ្ញាសំគាល់កងពលធំថ្មើរជើង លេខ ១៥។

មាត្រា២ : រចនាសម្ព័ន្ធចាត់តាំងភារកិច្ច និង សិទ្ធិរបស់កងពលធំថ្មើរជើងអាស្រ័យដោយអគ្គសេនាធិការកំណត់ ។

មាត្រា៣ : ប្រគល់ជូនអគ្គសេនាធិការកងយោធពលខេមរភូមិន្ទធ្វើការកំណត់ភារកិច្ច និង ពេលវេលាជាក់ស្តែងក្នុងការរៀបចំកងពលធំថ្មើរជើងខាងលើ ។

មាត្រា៤ : ក្រសួងការពារជាតិត្រូវទទួលបន្ទុកអនុវត្តន៍អនុក្រឹត្យនេះ ។

មាត្រា៥ : អនុក្រឹត្យនេះចូលជាធរមាន ចាប់ពីពេលឡាយព្រះហស្តលេខា និង ហត្ថលេខាតទៅ ។

ជ. រាជរដ្ឋាភិបាល

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
សម្តេចក្រុមព្រះ នរោត្តមរណឫទ្ធិ	សម្តេច ហ៊ុន សែន

អនុក្រឹត្យលេខ ៣៦ អនក្រ

ស្តីពី មុខងារនិងភារកិច្ច របស់ទីប្រឹក្សាក្រសួងការពារជាតិ

នៃរាជរដ្ឋាភិបាល ព្រះរាជាណាចក្រកម្ពុជា

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៤

- បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេច ព្រះនរោត្តម សីហនុវរ្ម័នព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆកា ឆ្នាំ ១៩៩៤ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សំរេច

ប្រការ ១ : ទីប្រឹក្សាក្រសួងការពារជាតិ មានភារកិច្ចដូចតទៅ :

ក- ជួយរដ្ឋមន្ត្រី ក្នុងវិស័យនយោបាយការពាជាតិ ជាពិសេសក្នុងការរៀបចំរចនាសម្ព័ន្ធការគ្រប់គ្រងការធ្វើឲ្យមានប្រសិទ្ធិភាពក្នុងកិច្ចបំរើការងារ និងកំណែនកងកំលាំងទាំងអស់ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធយោធាជាចាំបាច់ និងការរៀបចំអនុវត្តន៍ក្នុងវិស័យការពារផ្ទៃប្រទេស ។

ខ- សិក្សា និងស្នើមតិទៅរដ្ឋមន្ត្រី ដើម្បីធ្វើការណែនាំដល់គ្រប់នាយកដ្ឋានក្តី ភូមិភាគយោធាក្តី តំបន់សឹករងអង្គភាពក្តីក្នុងសកម្មភាពផលិតកម្មកិច្ចការពារប្រមូលផ្តុំ និងប្រើប្រាស់ធនធានគ្រប់ប្រភេទ ដើម្បីជាប្រយោជន៍ក្នុងកិច្ចការការពារជាតិ ។

គ-ធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រី នូវការវិវឌ្ឍន៍រាល់បញ្ហាដែលទាក់ទង និងការការពារជាតិក្នុងវិស័យនយោបាយក៏ដូចជាវិស័យបច្ចេកទេស ។

ប្រការ២ : ទីប្រឹក្សាត្រូវមានលេខាធិការដ្ឋានរួមមួយ ដើម្បីជាជំនួយការងារដោយមានបុគ្គលិកមួយចំនួនដែលមានក្របខ័ណ្ឌក្នុងក្រសួងស្រាប់ ។

ប្រការ ៣ : មានសិទ្ធិក្នុងការទាក់ទងគ្រប់នាយកដ្ឋាន អគ្គសេនាធិការយោធភូមិភាគ តំបន់ប្រតិបត្តិការសឹករង អង្គភាពកងអាកាសចរណ៍ខេមរភូមិន្ទ និង កងនាវាចរណ៍ខេមរភូមិន្ទ ក្រសួងមហាផ្ទៃនិងសន្តិសុខ ដើម្បីប្រមូលនូវព័ត៌មានណាដែលសំខាន់ក្នុងកិច្ចការការពារជាតិ ។

ប្រការ ៤ : ទីប្រឹក្សានឹងត្រូវបានទទួលភារកិច្ចបន្ថែមតាមការសំរេចរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ ។

ប្រការ ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងសន្តិសុខ នាយអគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឬទ្ធិ	ហ៊ុន សែន

***

អនុក្រឹត្យលេខ ៣៧ អនក្រ

ស្តីពីការបែងចែកសិទ្ធិចុះហត្ថលេខាលើ
អត្តសញ្ញាណប័ណ្ណ នាយទាហាន នាយទាហានរង
និង ពលទាហាន ខួធាំង កងយោធពលខេមរភូមិន្ទ

ភ្នំពេញថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៤

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញក្រឹត្យចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ១៩៩៣ ស្តីពីការចាត់តាំងបង្កើតក្រសួងការពារជាតិ និង អគ្គសេនាធិការដ្ឋាន

ប្រការ ៣ : មានសិទ្ធិក្នុងការទាក់ទងគ្រប់នាយកដ្ឋាន អគ្គសេនាធិការយោធភូមិភាគ តំបន់ប្រតិបត្តិការសឹករង អង្គភាពកងអាកាសចរណ៍ខេមរភូមិន្ទ និង កងនាវាចរណ៍ខេមរភូមិន្ទ ក្រសួងមហាផ្ទៃនិងសន្តិសុខ ដើម្បីប្រមូលនូវពត៌មានណាដែលសំខាន់ក្នុងកិច្ចការការពារជាតិ ។

ប្រការ ៤ : ទីប្រឹក្សានឹងត្រូវបានទទួលភារកិច្ចបន្ថែមតាមការសំរេចរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ ។

ប្រការ ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងសន្តិសុខ នាយអគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	ហ៊ុន សែន

* * *

អនុក្រឹត្យលេខ ៣៧ អនក្រ
ស្តីពីការបែងចែកសិទ្ធិចុះហត្ថលេខាលើ
អត្តសញ្ញាណប័ណ្ណ នាយទាហាន នាយទាហានរង
និង ពលទាហាន ជួរជាំង កងយោធពលខេមរភូមិន្ទ

ភ្នំពេញថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៤

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញក្រឹត្យចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ១៩៩៣ ស្តីពីការចាត់តាំងបង្កើតៗ ក្រសួងការពារជាតិ និង អគ្គសេនាធិការដ្ឋាន

-យោងតាមព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន រាជហរិវង្សឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និង នរោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- យោងតាមសំណើរបស់ក្រសួងការពារជាតិ អគ្គសេនាធិការ

សំរេច

មាត្រា១:-ត្រូវបានប្រគល់សិទ្ធិអោយក្រសួងការពារជាតិ និង អគ្គសេនាធិការ ចុះហត្ថលេខា លើអត្តសញ្ញាណប័ណ្ណ នាយទាហាន នាយទាហានរង ពលទាហានក្នុងកងយោធពលខេមរភូមិន្ទ ចាប់ពីយោធិន ដែលមានឋានន្តរសក្តិ ថ្នាក់វរៈសេនីយឯកចុះ ។

មាត្រា ២ : សហរដ្ឋមន្ត្រីក្រសួងការពារជាតិមានសិទ្ធិចុះហត្ថលេខាលើអត្តសញ្ញាណប័ណ្ណ នាយទាហាន ដែលស្ថិតចំណុះផ្ទាល់របស់ក្រសួងការពារជាតិ និង មានឋានន្តរសក្តិ ចាប់ពីថ្នាក់វរៈសេនីយឯកដល់នាយចំណាង ។

-នាយអគ្គសេនាធិការ មានសិទ្ធិចុះហត្ថលេខាលើអត្តសញ្ញាណប័ណ្ណ នាយទាហាន ដែលស្ថិតចំណុះផ្ទាល់របស់អគ្គសេនាធិការ និង មានឋានន្តរសក្តិចាប់ពីថ្នាក់វិរៈសេនីយឯកដល់នាយចំណាង ។

ចំពោះនាយទាហានរង ពលទាហាន ដែលមានឋានន្តរសក្តិពីថ្នាក់ព្រិន្ទបាល-ឯកដល់ ពលទោ អាស្រ័យដោយសហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង នាយអគ្គសេនាធិការ ប្រគល់សិទ្ធិជាក់ស្តែង ។

មាត្រា ៣:-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការត្រូវទទួលបន្ទុកអនុវត្តន៍តាមអនុក្រឹត នេះចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្ថលេខា និង ត្រា	ហត្ថលេខា និង ត្រា
សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ	សម្តេច ហ៊ុន សែន

* * *

សេចក្ដីសំរេច

រាជធានីភ្នំពេញ ,ថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ ១៩៩៤

សេចក្ដីសំរេចលេខ ៧៣ សសរ

ស្ដីពីប្រាក់អាហារបន្ថែមសម្រាប់កងយោធពលខេមរភូមិន្ទដែលមានរបួស ជំងឺ សំរាកព្យាបាលនៅតាមបន្ទីរពេទ្យ និងគិលានដ្ឋាន

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះករុណាព្រះ បាទសម្ដេចព្រះ នរោត្តមសីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិការ ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
-តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សំរេច

ប្រការ ១ : ដោយប្រាក់អាហារបន្ថែមសំរាប់កងយោធពលខេមរភូមិន្ទ ដែលមានរបួស ជំងឺសំរាកព្យាបាលនៅតាមបន្ទីរពេទ្យចំនួន ២.០០០ រ (ពីរពាន់រៀលគត់) ក្នុងមួយថ្ងៃ សំរាប់មួយនាក់ និង សំរាកព្យាបាលនៅតាមគិលានដ្ឋានចំនួន ១.៦០០ រ (មួយពាន់ប្រាំមួយរយរៀលគត់) ក្នុងមួយថ្ងៃសំរាប់មួយនាក់ ។

ប្រការ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងសុខាភិបាលត្រូវអនុវត្តតាមសេចក្ដីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្ត - លេខា និង ចុះហត្ថលេខាតទៅ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្ដលេខា និង ត្រា ហត្ថលេខា និង ត្រា

នរោត្តម រណឫទ្ធិ ហ៊ុន សែន

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ១៩៩៤

សេចក្តីសម្រេចលេខ ៧៤ សសរ
ស្តីពីការបង្កើតគណៈកម្មការពិសេស អង្កេតមជ្ឈមណ្ឌល
ឃុំឃាំង សម្ងាត់របស់កងយោធពលខេមរភូមិន្ទនៅខេត្តបាត់ដំបង
រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័នព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា .

-តាមសំណើរបស់ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

សម្រេច

ប្រការ ១: បង្កើតគណៈកម្មការពិសេស អង្កេតមជ្ឈមណ្ឌលឃុំឃាំងសម្ងាត់ របស់កងយោធពលខេមរភូមិន្ទនៅ ខេត្តបាត់ដំបង ដែលមានសមាសភាពដូចខាងក្រោម៖

១-តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	ប្រធាន
២-តំណាងក្រសួងយុត្តិធម៌	សមាជិក
៣-តំណាងក្រសួងការពារជាតិ	សមាជិក
៤-តំណាងក្រសួងមហាផ្ទៃ	សមាជិក
៥-តំណាងខេត្តបាត់ដំបង	សមាជិក

ប្រការ ២ : គណៈកម្មការពិសេសនេះ មានភារកិច្ចធ្វើការស្រាវជ្រាវស៊ើបអង្កេតជាបន្ទាន់ អំពីទីតាំងរបស់មជ្ឈមណ្ឌលឃុំឃាំង និង សកម្មភាពនានាដែលមជ្ឈមណ្ឌលបានអនុវត្តរំលោភបំពានទៅលើពិរុទ្ធជន ។

-បូកសរុបលទ្ធផល នៃការស្រាវជ្រាវ ដើម្បីរាយការណ៍ជូនគណៈរដ្ឋមន្ត្រី អោយបានមុនថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ១៩៩៤ ។

ប្រការ ៣ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបងត្រូវអនុវត្តតាមសេចក្តីសំរេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	ហ៊ុន សែន

• • •

រាជធានីភ្នំពេញ ,ថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៩៤

សេចក្តីសំរេចលេខ ៧៥ សសរ-សរ
ស្តីពីការផ្ទេរសិទ្ធិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១៦ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការងារចាំបាច់